## ករណីសិក្សា

# ខលមករស់នៅជាមួយគ្រួសារខញ្ញ!

នៅពេលដែលមានមានផ្ទៃពោះកូនប្រុសពៅទី៣បាន៧ខែ ប្តីរបស់នាងខ្ញុំមានជម្ងឺជាទម្ងន់ហើយក្លាយជាអ្នកវិកលចារិក។ ដោយសារគ្រួសារក្រីក្រមិនមានលទ្ធភាព កំណើតកូនទី៣នេះនាឆ្នាំ២០០០ នាងខ្ញុំបានសម្រេចចិត្តសម្រាលកូននៅឯផ្ទះដោយឆ្មបបុរាណ។ នេះជាសម្តីបងស្រី សៅ ចាន់ថា អាយុ៥៨ឆ្នាំនៅភូមិត្នោត ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ។



នៅឆ្នាំ ២០០៩ នាងខ្ញុំក៏ធ្លាក់ខ្លួនឈើជាទម្ងន់ទៀត នៅក្នុងគ្រួសារនេះគ្មានអ្នកណាជំហរជួយរកថវិកាដើម្បីទំនុកបំរុងគ្រួសារទេ។ ខ្ញុំក៏មិនមានថវិកាឯណាដើម្បីព្យាបាលដៃរខ្លួនឯងដែរ។ ដោយសារមេគ្រួសារទាំងពីរមានជម្ងឺប្រចាំកាយមិនមានលទ្ធភាពរកថវិកាដើម្បីផ្គត់ផ្គង់គ្រួសារបាន កូនប្រុសទី១ត្រូវបានឲ្យឈប់រៀនដើម្បីរកលុយជួយគ្រួសារ កូនស្រីទី២ជួយមើលថែទាំម្តាយឪពុក ហើយកូនប្រុសទី៣បានបញ្ជូនទៅរស់នៅជានឹងមួយគេ។

ដោយមើលឃើញពីការលំបាករបស់គ្រួសារបងស្រី ក្រុមការងាររបស់អង្គការភីស៊ី សហការជាមួយមេភូមិត្នោត បានជ្រើសរើសគ្រួសារបងស្រីចាន់ជាគ្រួសារក្រីក្រចូលក្នុងគម្រោង។



**ឡេង ខង** មានបងប្អូន៣នាក់ជាកូនទី៣ប្រុសពៅមានអាយុ១៩ឆ្នាំ ម្តាយបានបញ្ជូនទៅរស់នៅជាមួយគេដោយសារគ្រួសារក្រីក្រគ្មានលទ្ធភាពចិញ្ចឹមបីបាច់តាំងតែមានអាយុ១០ឆ្នាំម្ល៉េះ។

ក្រោយពីបានការគាំទ្រពីអង្គការ **ខង** ឈប់រស់នៅជាមួយគេ ហើយបានវិលត្រឡប់មករស់ជួបជុំគ្រួសារវិញ និងបានបន្តការសិក្សានៅសាលាក្បែរភូមិកំណើតនៅថ្នាក់ទី៥ក្នុងឆ្នាំ២០១៣នេះ។

តាមសម្តីរបស់ **ខង** បានសង្កត់ថា៖ ពេលដែលរស់នៅជាមួយគេ មិនសូវបានសប្បាយចិត្តទេពីព្រោះនឹកម្តាយឪពុកនិងគ្រួសារ មានអារម្មណ៍ហាក់ដូចជាអាណិតខ្លួន ពេលខ្លះយំតែម្នាក់ឯងក៏មាន។ ពេលនេះខ្ញុំបាទបានមកនៅជួបម្តាយឪពុកបងៗ មានចិត្តសប្បាយរីកនិងមានសេចក្តីសង្ឃឹមជាខ្លាំង។ ខ្ញុំគិតថា មានការគាំទ្រពីអង្គការនិងគ្រួសារ ខ្ញុំពិតជាមានឱកាសសិក្សាឲ្យមានតម្រេះវិជ្ជាដូចកុមារនៅក្នុងភូមិនេះដែរ ជាពិសេសមិនមានភាពឯកោទៀតទេ។